## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ១៧៥ ទក

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០១៥

# ប្រកាស
# ស្តីពី
# ការលើកទឹកចិត្តចំពោះជ័យលាភីនៃការប្រឡងប្រណាំងរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១២៣អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការបង្កើតរង្វាន់ពិសេសសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍
- យោងតាមតម្រូវការចាំបាច់នៃការងារ។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលដៅកំណត់នូវប្រភេទនៃការលើកទឹកចិត្តសម្រាប់ផ្តល់ជូនសហគ្រាសគំរូ ឬបុគ្គលគំរូ ដែលបានជាប់ជាជ័យលាភីនៃ**រង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍**។

ផ្ទះលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.mot.kh

**ប្រការ២.-**

នៅក្នុងកំឡុងពេលសុពលភាពនៃរង្វាន់ ជ័យលាភីនីមួយៗអាចទទួលបាននូវបុព្វសិទ្ធិ និងការលើកទឹកចិត្តផ្សេងៗ ដូចខាងក្រោម៖

- ម្ចាស់ជ័យលាភីមានសិទ្ធិប្រើប្រាស់តែស្លាកសញ្ញាដែលសាមីខ្លួនទទួលបាន ដើម្បីផ្សព្វផ្សាយទៅភ្ញៀវជាតិ-អន្តរជាតិ ព្រមទាំងអាចបោះពុម្ពលើខិត្តប័ណ្ណផ្សព្វផ្សាយពាណិជ្ជកម្ម និងដាក់ក្នុងគេហទំព័រផ្ទាល់ខ្លួន
- កាត់បន្ថយថ្លៃចេញអាជ្ញាបណ្ណទេសចរណ៍
- ទទួលបាននូវអាទិភាពក្នុងយុទ្ធនាការផ្សព្វផ្សាយ និងមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្លូវការនានា មានជាអាទិ៍៖
  - ផ្សព្វផ្សាយនៅលើគេហទំព័រផ្សព្វផ្សាយផ្លូវការរបស់ក្រសួងទេសចរណ៍
  - ចូលរួមការតាំងពិព័រណ៍ក្នុង ឬក្រៅប្រទេសដោយមិនគិតថ្លៃ ចំនួនពីរ(២)ដង
  - ផ្សព្វផ្សាយនៅលើសៀវភៅ និងសម្ភារៈផ្សព្វផ្សាយរបស់ក្រសួងទេសចរណ៍
- ក្លាយជាសមាជិកនៃ “បណ្តាញធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍”។

**ប្រការ៣.-**

ជ័យលាភីទាំងអស់ត្រូវបានដាក់បញ្ចូលទៅក្នុងសៀវភៅបញ្ជីជ័យលាភីដែលមានឈ្មោះថា “**បញ្ជីជ័យលាភីធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍**” ហើយដែលត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ។

**ប្រការ៤.-**

បង្កើតនូវគេហទំព័រ ដើម្បីផ្សព្វផ្សាយម្ចាស់ជ័យលាភីនៃ “**រង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍**” ដែលមានអាស័យដ្ឋាន www.cambodiaecobusiness.org។

**ប្រការ៥.-**

ត្រូវបានចាត់ទុកជានិរាករណ៍ប្រកាសលេខ ១៦៨ ប្រក ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៥ ស្តីពីការលើកទឹកចិត្តសម្រាប់ជ័យលាភីធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការនៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកទេសចរណ៍ នាយកខុទ្ទកាល័យអធិការ ក្រុមអ្នកច្បាប់ប្រធានគ្រប់នាយកដ្ឋាន ប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្តត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

***កន្លែងទទួល:***

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារកាលប្បវត្តិ